**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ ០១២/២០០៣ កបធ.សជណ.ច

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣

**ជំរាបមក**

**លោក លឺវ អាន ប្រធានគណបក្សចំរើននិយមខ្មែរ**

**កម្មវត្ថុ** : អំពីបណ្ដឹងតវ៉ាចំពោះសេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ០៥.៧៩៦/០៣ គ.ជ.ប ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៣

**យោង** : លិខិតរបស់លោក លេខ ១០៤/០៣ ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៣

តបតាមលិខិតរបស់លោកដូចមានក្នុងកម្មវត្ថុ និង យោងខាងលើខ្ញុំមានកិត្តិយសជំរាបលោកថាក្រុមប្រឹក្សាធម្មនុញ្ញពុំអាចអនុគ្រោះ តាមសំណូមពររបស់លោកបានទេ ពីព្រោះការដែលមិនបានបំពេញបន្ថែមល័ក្ខខ័ណ្ឌទាំងពីរចំណុច គឺចំណុចទី៤ និង ចំណុចទី១០ នៃមាត្រា ៣៧ ថ្មី នោះ ឱ្យទាន់ក្នុងរយៈពេលកំនត់ដោយច្បាប់ត្រូវចាត់ទុកថា គណបក្សលោកបានបោះបង់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតដូចមានចែងក្នុងវាក្យខ័ណ្ឌចុងក្រោយនៃ មាត្រា ៤០ថ្មី នៃព្រះរាជក្រមនស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ប្រកាសឱ្យប្រើច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រហើយ ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ប៊ិន ឈិន**